# កំណាព្យ៖ ទិវានារី (បទបន្ទោលកាក)

ប្រាំបីមីនា គឺជាទិវានារី
ដែលបានពលី កម្លាំងជីវិតកាយចិត្ត។
តស៊ូតវ៉ា ដោយភាពហានក្លាសុំសិទ្ធិ
ស្មើបុរសពិត ទាំងកម្លាំងចិត្តបញ្ញា។
សុំសិទ្ធិបញ្ឈប់ ការរើសអើងគ្រប់ផងណា
សុំសិទ្ធិធ្វើការ មិនប្រកាន់ការឡើយនែ។
សុំសិទ្ធិសម្រេច រាល់គ្រប់ការកិច្ចអ្វីៗ
ទោះនយោបាយក្តី គ្រប់រូបស្ត្រីអាចធ្វើ។
ការងារក្នុងក្រៅ នារីអាចដៅអាចមើល
នូវរាល់ទង្វើ ឥតមានស្មាក់ស្មើរឡើយណា។
គ្រប់រូបនារី មានតួនាទីថ្លៃថ្លា
ធ្វើសព្វកិច្ចការ មិនថាការងារធ្ងន់ស្រាល។
នារីរួមចិត្ត សហការពិតរុញច្រាន
ជួយអភិបាល សង្គមជាតិបានថ្កុំថ្កើង។
សព្វគ្រប់នាទី នារីសំភីទ្វេឡើង
ជួយលើកតម្កើង ជាតិឱ្យថ្កុំថ្កើងភិសម័យ។
នារីខិតខំ ប្រមូលពូតផ្តុំស្នាដៃ
ការងារចាស់ថ្មី នារីលែកលៃធ្វើគ្រប់។
មិនដែលរាថយ ដូចមានដៃ១០០ឥតឈប់
ធ្វើទាំងថ្ងៃយប់ ព្រលឹមព្រលប់កាន់ការ។
ដូច្នេះបុរស គួរផ្តល់កិត្តិយសផងណា
ចាត់ទុកស្ត្រីថា ជីដូនមាតាបងប្អូន។
ឬបុរសគិត ថាស្ត្រីនោះពិតដូចកូន
ធ្វើខ្លួនដូចក្បូន ជួយចម្លងកូនដល់ត្រើយ។
នាពេលបុរស បានផ្តល់កិត្តយសនោះហើយ
រីស្ត្រីយើងអើយ ចូរនាងខំថែរក្សា។

ឱ្យសក្តិសមពិត នឹងតម្លៃពិតពោលថា
ស្ត្រីជាមាតា នៅលើលោកាពិតៗ។
បុរសនារី ត្រូវគិតសំកីរួមចិត្ត
ពួតដៃគ្នា ពិត រក្សានូវសិទ្ធិស្ត្រី។
ធ្វើជាប្រចាំ រាល់ថ្ងៃខែឆ្នាំនោះនៃ
លើកនូវតម្លៃ មិនមែនមួយថ្ងៃនេះឡើយ។
បើយើងធ្វើបាន នោះភាពសុខសាន្តមានហើយ
យើងកុំភ្លេចឡើយ ប្រារព្ធទិវាចងចាំ។
ដើម្បីអបអរ ស្វាគមន៍សាទរប្រចាំ
ឱ្យយើងចំណាំ នារីមានសិទ្ធិគ្រប់គ្រា៕

*បាងកក ៨ មីនា ២០២០*

*ដោយៈ លោកស្រីបណ្ឌិត ជា វណ្ណី*